**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ១១ សជណន

# សារាចរណែនាំ
# ស្តីពី
# ការចូលរួមគោរពព្រះវិញ្ញាណក្ខន្ធព្រះបរមសព ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ

ដើម្បីចូលរួមគោរពព្រះវិញ្ញាណក្ខន្ធព្រះបរមសព **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ និងជាព្រះស្វាមី **សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ដែលព្រះអង្គបានសោយទិវង្គត នៅថ្ងៃទី ១៥ រោជ ខែ ភទ្របទ ឆ្នាំ រោង ចត្វាស័ក ព.ស.២៥៥៦ ត្រូវនឹងថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០១២ វេលាម៉ោង ០១:២០ នាទី រំលងអធ្រាត្រ (ម៉ោងនៅរាជធានីភ្នំពេញ) ក្នុងព្រះជន្មាយុ ៩០ ព្រះវស្សា ដោយព្រះជរាពាធ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចតទៅ ៖

១. ប្រកាសថ្ងៃកាន់ទុក្ខគោរពព្រះវិញ្ញាណក្ខន្ធ ជាផ្លូវការរយៈពេល ០៧ ថ្ងៃ ចាប់ពីថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១២ រហូតដល់ ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ ។

២. ក្នុងរយៈពេលកាន់ទុក្ខនេះ គ្រប់ស្ថាប័នរដ្ឋ និងឯកជន ព្រមទាំងប្រជាពលរដ្ឋទូទាំងប្រទេស ត្រូវបង្ហូតទង់ជាតិ ត្រឹម ១/៣ (មួយភាគបី) នៃដងទង់ជាតិ ចាប់ពីលើ ។

៣. គ្រប់ស្ថានីយ៍វិទ្យុនិងទូរទស្សន៍ជាតិ និងឯកជន ព្រមទាំងកន្លែង កំសាន្តសប្បាយ ត្រូវផ្អាក ការផ្សាយនូវទស្សនីយភាព ការសម្តែង និងការប្រគុំតន្ត្រីផ្សេងៗ ដែលមានលក្ខណៈ សប្បាយគគ្រឹកគគ្រេង ក្នុងរយៈពេល៧ថ្ងៃនេះ។

៤. គ្រប់ស្ថានទូត និងស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវត្រៀមរៀបចំ ទីកន្លែង ព្រះឆាយាលក្ខណ៍ នៃ **ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ** និងសៀវភៅសម្រាប់ចុះអារម្មណ៍ទុក្ខ។

កាលបរិច្ឆេទជាក់ស្តែង ដែលអនុញ្ញាតឱ្យភ្ញៀវទាំងអស់អញ្ជើញចូលរួមមរណទុក្ខ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនឹងជូនព័ត៌មាននៅពេលក្រោយ ។

៥. ប្រជាពលរដ្ឋគ្រប់ៗរូប ពាក់សញ្ញាកាន់មរណទុក្ខ និងតុបតែងសញ្ញាកាន់មរណទុក្ខនៅលើព្រះឆាយាលក្ខណ៍ក្នុងរយៈពេលកាន់ទុក្ខនេះ។

៦. ខាងលើនេះគឺជាការកាន់មរណទុក្ខលើកទី១។ ព្រះបរមសពនឹងត្រូវតម្កល់ទុកក្នុងរយៈពេលមិនតិចជាង៣ខែនៅព្រះបរមរាជវាំង មុនពេលប្រារព្ធព្រះរាជពិធីបូជាព្រះបរមសព ហើយកាលបរិច្ឆេទជាក់ស្តែងនៃព្រះរាជពិធីបូជាព្រះបរមសព នឹងជម្រាបជូននៅពេលក្រោយ។ ក្នុងរយៈពេល៣ខែនេះ មន្ត្រីរាជការ ប្រជាពលរដ្ឋ និងមិត្តភក្តិបរទេសទាំងអស់អាចចូលមកគោរពព្រះវិញ្ញាណក្ខន្ធបាន។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន គ្រប់អាជ្ញាធរមានសមត្ថកិច្ច អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ គ្រប់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ព្រមទាំងជនរួមជាតិ ប្រជាជនទូទាំងប្រទេសត្រូវចូលរួមអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីជាកិច្ចចូលរួមមរណទុក្ខដ៏ក្រៀមក្រំរកទីបំផុតគ្មាននេះ។

ធ្វើនៅថ្ងៃទី១៥ ខែ តុលា ឆ្នាំ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ចម្លងជូន:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន
- គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី ខេត្ត
- ឯកសារ-កាលប្បវត្តិ